# សាលាបឋមសិក្សា សោថហ្វក (SOUTHWARK)


1835 S. 9th Street
Philadelphia, PA 19148
**ការិយាល័យ៖ 215-952-8606**
**ទូរសារ៖ 215-952-8670**

**Andrew Lukov**, នាយកសាលា


## <u>ច្បាប់សម្រាប់ ពេលមកដល់សាលា និង ពេលចេញពីសាលា របស់សាលាបឋមសិក្សា សោថ់ហ្វក</u>

### ពេលមកដល់សាលា

- ថ្ងៃរៀនគឺចាប់ពីម៉ោង ៨:៣០ ព្រឹក ដល់ ម៉ោង ៣:០៩ រសៀល។
- សាលញ៉ាំបាយ បើកនៅម៉ោង ៨:០០ ព្រឹក សម្រាប់អាហារពេលព្រឹក។
- បុគ្គលិកម្នាក់នឹងនៅក្នុង ទីធ្លាសាលា និង សាលញ៉ាំបាយ នៅម៉ោង ៨:០០ ព្រឹក។
- **សំខាន់៖ សិស្សានុសិស្សមិនត្រូវនៅក្នុងបរិវេណសាលា មុនម៉ោង ៨:០០ ព្រឹក ទេ។**
- អ្នកចូលសាលាពេលព្រឹកទាំងអស់ គឺពីម៉ោង ៨:០០ ដល់ ម៉ោង ៨:៣០ ព្រឹក ត្រូវចូលតាមទ្វារសាលញ៉ាំបាយ។ ត្រូវធ្វើតាមវិន័យនេះ ដោយគ្មានការលើកលែងអ្វីឡើយ។
- ដើម្បីរក្សា សុវត្ថិភាព និង សន្តិសុខ ទ្វារនៅផ្លូវលេខ៨ នឹងមិនអនុញ្ញាតឲ្យប្រើទេ នៅថ្ងៃរៀន។ ទាំងនេះគឺជាទ្វារចេញនៅពេលមានអាសន្នតែប៉ុណ្ណោះ។
- នៅពេលញ៉ាំអាហារពេលព្រឹក សិស្សត្រូវនៅក្នុងសាលញ៉ាំបាយ។ លើកលែងតែពេលត្រូវប្រើបន្ទប់ទឹក ដែលស្ថិតនៅក្រៅសាលញ៉ាំបាយ។
- យើងស្វាគមន៍មាតាបិតាក្នុងការជូនកូនទៅកាន់សាលញ៉ាំបាយ ប៉ុន្តែត្រូវតែនៅក្នុងសាលញ៉ាំបាយ កុំដើរទៅណា។
- នៅពេលញ៉ាំអាហារពេលព្រឹក គេមិនអនុញ្ញាតឲ្យ សិស្ស និង មាតាបិតា ចេញពីសាលញ៉ាំបាយ ទៅកាន់កន្លែងផ្សេងៗនៅក្នុងអាគារសាលាទេ។
- យើងស្វាគមន៍សិស្សឲ្យលេងដោយមានការទទួលខុសត្រូវ នៅកន្លែងសម្រាប់ក្មេងលេង នៅក្នុងទីធ្លាសាលា។ ដោយសារមានក្មេង តូចៗនៅក្នុងទីធ្លាសាលា ហាមមិនឲ្យលេង បាល់អោប និង បាល់ទាត់ ដែលមានស្បែករឹងនោះទេ។
- សិស្សចាប់ផ្តើមតម្រង់ជួរនៅម៉ោង ៨:២៥ ព្រឹក ក្នុងទីធ្លាសាលា។
- គ្រូនាំសិស្សចូលថ្នាក់នៅម៉ោង ៨:៣០ ព្រឹក។
- នៅម៉ោង ៨:៣០ ព្រឹក យើងនឹងឲ្យមនុស្សចេញពីសាលញ៉ាំបាយទាំងអស់ ដើម្បីយើងអាចចាប់ផ្តើមរៀបចំអាហារថ្ងៃត្រង់។ មាតាបិតាទាំងអស់ត្រូវចេញពីអាគារតាមទ្វារសាលញ៉ាំបាយ។ ដើម្បី កុំឲ្យចង្អៀត និង រក្សាសន្តិសុខ គេមិនអនុញ្ញាតឲ្យមាតាបិតាចេញតាមទ្វារផ្លូវលេខ៨ និង ផ្លូវលេខ៩ ទេ។
- នៅពេលសិស្សចូលក្នុងអាគារនៅម៉ោង ៨:៣០ ព្រឹក គេមិនអនុញ្ញាតឲ្យមាតាបិតាចូលតាមកូនទៅក្នុងអាគារទេ។ មាតាបិតាណាដែលចង់ ជួបជាមួយរដ្ឋបាល ត្រូវយកស្លាកពាក់ដើរសម្រាប់អ្នកមកកាន់សាលា ដោយចូលតាមទ្វារផ្លូវលេខ៩ ហើយទៅកាន់ការិយាល័យសាលា។
- សិស្សថ្នាក់មត្តេយ្យតម្រង់ជួរនៅក្នុងសាលញ៉ាំបាយ។
- សិស្សមុនថ្នាក់មត្តេយ្យតម្រង់ជួរនៅក្រៅបន្ទប់ B-21 ដោយប្រើផ្លូវចូលនៅចំហៀងនៃទីធ្លាសាលា។
- សិស្សណាដែលមកដល់ក្រោយម៉ោង ៨:៣០ ព្រឹក ចាត់ទុកថាមកយឺតពេល ហើយត្រូវចូលអាគារតាមទ្វារផ្លូវលេខ៩ និងយកសំបុត្រសម្រាប់អ្នកមកយឺតពេល។

### ពេលចេញពីសាលា

- សិស្សមុនថ្នាក់មត្តេយ្យទាំងអស់ចេញតាមផ្លូវចូល នៅចំហៀងនៃទីធ្លាសាលា ហើយត្រូវចុះហត្ថលេខាពេលចេញជារៀងរាល់ថ្ងៃ។
- សិស្សថ្នាក់មត្តេយ្យទាំងអស់ចេញទៅទីធ្លាចតឡានតាមទ្វារផ្លូវលេខ៩ ហើយត្រូវចុះហត្ថលេខាពេលចេញជារៀងរាល់ថ្ងៃ។ សូមកត់សម្គាល់ថា សិស្សថ្នាក់មត្តេយ្យ នឹងចេញតាមសាលញ៉ាំអាហារ នៅពេលណាមានអាកាសធាតុមិនល្អ។
- សិស្សថ្នាក់ទី១-ទី៥ ទាំងអស់ ចេញទៅទីធ្លាសាលា តាមផ្លូវដែលពួកគេចូលនៅពេលព្រឹក។
- សិស្សថ្នាក់ទី៦-ទី៨ ទាំងអស់ ចេញទៅចិញ្ចើមផ្លូវតាមទ្វារផ្លូវលេខ៩។
- មាតាបិតាអាចចាប់ផ្តើមចាំទទួលកូននៅក្នុងទីធ្លាសាលា ចាប់ពីម៉ោង ២:៥០ រសៀល។
- សូមជ្រាបថា ភ្លៀង ឬ បើកថ្ងៃ មាតាបិតាមិនអាចចាំនៅក្នុងអាគារបានទេ ដើម្បីរក្សាសុវត្ថិភាព។
- នៅម៉ោងចេញពីរៀន មាតាបិតាមិនអាចចូលក្នុងអាគារតាមទ្វារផ្លូវលេខ៨បានទេ។
- ដើម្បីធ្វើយ៉ាងណាឲ្យមានការមើលខុសត្រូវឲ្យបានដិតដល់នៅពេលសិស្សចេញពីរៀន រដ្ឋបាលមិនអាចជួបជាមួយមាតាបិតាបានទេពីម៉ោង ២:៥៥ រហូតដល់ម៉ោង ៣:៣០ រសៀល។

## វិន័យសម្រាប់សិស្សនៅពេលចេញពីរៀន

- ចេញពីសាលា ត្រូវតម្រង់ទៅផ្ទះ។
- នៅម៉ោងចេញពីរៀន សិស្សត្រូវទទួលខុសត្រូវក្នុងការគោរពតាមវិន័យទាំងអស់របស់សាលា។
- ដើរលើចិញ្ចើមផ្លូវ ឆ្លងត្រង់កន្លែងកាច់ជ្រុង និង ចោលសម្រាមទៅក្នុងធុងសម្រាម។
- ស្តាប់តាមសមាជិកសហគមន៍ និងអ្នកនាំក្មេងឆ្លងផ្លូវ របស់យើង។
- **សំខាន់៖ សិស្សមិនអាចនៅក្នុងអាគារ ឬ បរិវេណសាលា បានទេ ក្រោយម៉ោងសិក្សា លើកលែងតែពួកគេចូលរួមក្នុងកម្មវិធីក្រោយម៉ោងសិក្សា ឬ មានសមាជិកបុគ្គលិកណាម្នាក់នៅមើលខុសត្រូវ។**

## ចេញមុនម៉ោង

- ការសុំអនុញ្ញាតចេញពីអាគារត្រូវសុំពីការិយាល័យសាលា។
- **សំខាន់៖ សិស្សត្រូវចុះហត្ថលេខាពេលចេញ នៅការិយាល័យសាលា។**
- មាតាបិតា ឬ អ្នកតំណាងពេញវ័យ (លើសពី២១ឆ្នាំ) អាចមកទទួលសិស្សបាន។
- អ្នកតំណាងដែលជាមនុស្សពេញវ័យ ត្រូវមានឈ្មោះនៅក្នុងលិខិតសម្រាប់ទាក់ទងនៅពេលមានអាសន្នរបស់សិស្ស ហើយត្រូវមានអត្តសញ្ញាណប័ណ្ណ។
- មិនអនុញ្ញាតឲ្យចេញមុនម៉ោងបានទេ ក្រោយម៉ោង ២:៣០ រសៀល។
- សិស្សត្រូវទទួលខុសត្រូវចំពោះកិច្ចការដែលខ្លួនមិនបានធ្វើ។

## កម្មវិធីក្រោយម៉ោងសិក្សា

- សិស្សដែលចូលរួមក្នុងកម្មវិធីក្រោយម៉ោងសិក្សា ត្រូវទៅកាន់កន្លែងដែលគេចាត់ឲ្យទៅជាបន្ទាន់។
- សិស្សដែលចូលរួមក្នុងកម្មវិធីក្រោយម៉ោងសិក្សា មិនអាចចេញពីអាគារនៅពេលសិស្សចេញពីរៀន ហើយបន្ទាប់មកចូលអាគារវិញ ដើម្បីចូលរួមក្នុងកម្មវិធីក្រោយម៉ោងសិក្សារបស់ពួកគេ បានទេ។
- សិស្សមិនអាចចាំបងប្អូនដែលត្រូវនៅក្រោយម៉ោងសិក្សាបានទេ។

# <u>ច្បាប់វត្តមានអវត្តមានរបស់សាលា សោថ្វាក</u>

## មករៀនមិនទាន់ពេល

- សិស្សដែលមកដល់ក្រោយម៉ោង ៨:៣៥ ព្រឹក ត្រូវគេកត់ទុកថាមករៀនយឺតពេល ហើយត្រូវចូលតាមទ្វារផ្លូវលេខ៩ ដើម្បីយកសំបុត្រសម្រាប់អ្នកមករៀនយឺតពេល។
- ការមករៀនមិនទាន់ពេលច្រើនដងនឹងបណ្តាលឲ្យមានការដាក់វិន័យ។
- មាតាបិតាមិនអាចជូនកូនទៅថ្នាក់រៀនបានទេ។
- សិស្សត្រូវទទួលខុសត្រូវចំពោះកិច្ចការដែលខ្លួនមិនបានធ្វើ។
- បើសិនជាសិស្សមកដល់ក្រោយ ម៉ោង ១០ ព្រឹក ឬ ចេញមុន ម៉ោង ១ រសៀល ដោយគ្មានលិខិតអនុញ្ញាតត្រឹមត្រូវ គេនឹងកត់ទុកថា សិស្សឈប់ដោយគ្មានមូលហេតុ កន្លះថ្ងៃ។
- ឈប់កន្លះថ្ងៃពីរដង រាប់ថាឈប់ដោយគ្មានមូលហេតុមួយថ្ងៃ។

## វត្តមានអវត្តមាន

- ដោយសារវត្តមានអវត្តមាន គឺជាគន្លឹះក្នុងការទទួលជោគជ័យនៅសាលា សាលាតាមដានវត្តមានអវត្តមានយ៉ាងប្រុងប្រយ័ត្ន។
- ត្រូវផ្តល់លិខិតបញ្ជាក់ពីមូលហេតុនៃអវត្តមានក្នុងកំឡុងពេលបី (៣) ថ្ងៃ រាប់ចាប់ពីថ្ងៃអវត្តមាន។ បើសិនជាមិនបានផ្តល់លិខិតបញ្ជាក់ពីមូលហេតុក្នុងកំឡុងពេលបី (៣) ថ្ងៃទេ អាចបណ្តាលឲ្យសាលាចាត់ទុកអវត្តមាននេះថា ខុសច្បាប់/គ្មានមូលហេតុ ដោយមិនអាចកែប្រែបាន។
- <u>សាលានឹងធ្វើតាមច្បាប់ បើសិនជាអវត្តមានគ្មានមូលហេតុ កើតឡើងម្តងហើយម្តងទៀត។</u>
- សាលានឹងជម្រាបទៅមាតាបិតា ក្រោយពីសិស្សអវត្តមានបីដង។
- ក្រោយពីអវត្តមានប្រាំបួន (៩) ដង ដោយសារជម្ងឺ ដែលមាតាបិតាបានសរសេរលិខិតសុំការលើកលែង អវត្តមានលើកទី១០ ដោយសារជម្ងឺ ត្រូវមានលិខិតបញ្ជាក់ពីវេជ្ជបណ្ឌិត ភ្ជាប់មកជាមួយ។